LES ENFANTS DE KLANG LEU

STATUTS

### Article 1 - Constitution

Il est fondé entre les adhérents aux présents statuts une association régie par la loi du 1er juillet 1901 et le décret du 16 août 1901, ayant pour titre : **Les Enfants de Klang Leu**

### Article 2 - Objet

Cette association a pour but :
1. Assurer le bon fonctionnement de la crèche de Klang Leu, petite ville en banlieue de Sihanoukville – Cambodge.
2. Aider les familles dont les enfants vont régulièrement à la crèche en améliorant leurs conditions de vie sur le plan santé, hygiène, logement et éducation scolaire.

### Article 3 - Siège social

Le siège social est fixé à l'adresse suivante :
15 rue du Docteur Kerjean 29200 BREST
Il pourra être transféré par simple décision du conseil d'administration ; la ratification par l'assemblée générale sera nécessaire.

### Article 4 - Membres

L'association se compose de personnes physiques et morales :
a) Membres bienfaiteurs
b) Membres d'honneur
Sont membres bienfaiteurs les personnes qui effectuent une donation.
Sont membres d'honneur ceux qui ont rendu des services signalés à l'association

### Article 5 - Radiations

La qualité de membre de l'association se perd :
a) La démission ;
b) Le décès ;
c) La radiation prononcée par le conseil d'administration pour motif grave, l'intéressé ayant été invité par lettre recommandée à se présenter devant le bureau pour fournir des explications.

### Article 6 - Ressources

Les ressources de l'association comprennent :
1. Le montant des dons réguliers ou ponctuels ;
2. Les subventions de l'Etat, des régions, des départements et des communes.

### Article 7 - Conseil d'administration

L'association est dirigée par un conseil d'au moins trois membres, élus pour 5 années par l'assemblée générale. Les membres sont rééligibles.
Le conseil d'administration choisit parmi ses membres, au scrutin secret, un bureau composé de trois membres :

- Un(e) président(e) ;
- Un(e) secrétaire ;
- Un(e) trésorier(e).

En cas de vacance, le conseil pourvoit provisoirement au remplacement de ses membres. Il est procédé à leur remplacement définitif par la plus prochaine assemblée générale. Les pouvoirs des membres ainsi élus prennent fin à l'époque où devrait normalement expirer le mandat des membres remplacés.

### Article 8 - Réunion du conseil d'administration

Le conseil se réunit une fois au moins une fois par an, sur convocation du président, ou sur la demande du quart de ses membres.
Les décisions sont prises à la majorité des voix ; en cas de partage, la voix du président est prépondérante.
Tout membre du conseil qui, sans excuse, n'aura pas assisté à trois réunions consécutives pourra être considéré comme démissionnaire.

### Article 9 - Assemblée générale ordinaire

L'assemblée générale ordinaire comprend tous les membres de l'association à quelque titre qu'ils soient affiliés.
L'assemblée générale ordinaire se réunit chaque année au moins une fois par an. Quinze jours au moins avant la date fixée, les membres de l'association sont convoqués par les soins du secrétaire. L'ordre du jour est indiqué sur les convocations.
Le président, assisté des membres du bureau, préside l'assemblée et expose la situation morale de l'association.
Le trésorier rend compte de sa gestion et soumet le bilan à l'approbation de l'assemblée.
Il est procédé, après épuisement de l'ordre du jour, au remplacement, au scrutin secret, des membres du conseil sortants.
Ne devront être traitées, lors de l'assemblée générale, que les questions soumises à l'ordre du jour.

### Article 10 - Assemblée générale extraordinaire

Si besoin est, ou sur la demande de la moitié plus un des membres inscrits, le président peut convoquer une assemblée générale extraordinaire, suivant les formalités prévues à l'article 9.

### Article 11 - Règlement intérieur

Un règlement intérieur peut être établi par le conseil d'administration, qui le fait alors approuver par l'assemblée générale. Ce règlement éventuel précise certains points des statuts, notamment ceux qui ont trait à l'administration interne de l'association.

### Article 12 - Dissolution

En cas de dissolution prononcée par les deux tiers au moins des membres présents à l'assemblée générale, un ou plusieurs liquidateurs sont nommés par celle-ci et l'actif, s'il y a lieu, est dévolu conformément à l'article 9 de la loi du 1er juillet 1901 et au décret du 16 août 1901.

**Statuts approuvés par l'assemblée générale extraordinaire du 3 avril 2019.**

La Présidente — La Secrétaire

G. DELBARD

ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា ព្រះមហាក្សត្រ

~~~~~~~

# លក្ខន្តិកៈ

## អង្គការកុមារឃ្លាំងលើ

## ( អកឃ )

ទីស្នាក់ការ ផ្លូវលេខលំ ភូមិលេខ០១ សង្កាត់០១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
~~~~~~~

# <u>លក្ខន្តិកៈ</u>

## អង្គការកុមារឃ្លាំងលើ

## <u>ជំពូកទី ១</u>

### អំពីគោលបំណង ទិសដៅ និងយុទ្ធសាស្ត្រ

**ប្រការ១ : គោលបំណង**

គោលបំណងរបស់អង្គការគឺ

-ជួយបណ្តុះបណ្តាលក្រៅម៉ោង

-ផ្តត់ផ្គង់ចំណីអាហារ ថែរក្សាអនាម័យ

-ចូលរួមសកម្មភាពសិក្សាអប់រំ និងផ្តល់ជំនួយទៅគ្រួសារក្មេងៗម្តងម្កាល។

**ប្រការ២ : ទិសដៅ**

-លើកស្ទួយវិស័យអប់រំ

-ជួយលើកស្ទួយអនាម័យលើកុមារ

-លើកស្ទួយគាំពារសុខភាពកុមារ ។

**ប្រការ៣ : យុទ្ធសាស្ត្រ**

-ជួយជំរុញឲ្យកុមារចូលសាលា

-ជួយជំរុញការប្រើប្រាស់ចំណីអាហារមានអនាម័យ

-ជួយជំរុញឲ្យកុមារចេះថែរក្សាសុខភាព ។

## <u>ជំពូកទី ២</u>

### អំពីឈ្មោះ អាសយដ្ឋាន អត្តសញ្ញាណ និងសញ្ញាសម្គាល់

**ប្រការ៤ : អំពីឈ្មោះ**

អង្គការនេះមានឈ្មោះថា " អង្គការកុមារឃ្លាំងលើ " សរសេរអក្សរកាត់ " អកឃ " និងមានឈ្មោះជាភាសាបារាំងថា " Les Enfants De Klang Leu " សរសេរអក្សរកាត់ " EKL " ។

**ប្រការ៥ : អាសយដ្ឋាន**

អង្គការមានទីស្នាក់ការកណ្តាលតាំងនៅខេត្តព្រះសីហនុ ។ អង្គការអាចមានទីស្នាក់ការសាខានៅតាមបណ្តាលរាជធានីខេត្តនានាតាមតម្រូវការចាំបាច់របស់អង្គការ ។ ក្នុងករណីចាំបាច់សមាគមអាចផ្លាស់ប្តូរទីស្នាក់ការបានតាមសំឡេងគាំទ្រ២/៣នៃសមាជិកគណៈកម្មការប្រតិបត្តិ ។

**ប្រការ៦ : អត្តសញ្ញាណ**

អង្គការកុមារឃ្លាំងលើ គឺជាអង្គការមិនស្វែងរកកម្រៃជាឯកជន អព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍នយោបាយ ក្នុងនោះមានរួម

ទាំងមិនផ្តល់មធ្យោបាយជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្សដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬ អ្នកគាំទ្រណាមួយឡើយ ប៉ុន្តែគឺជាអង្គការបម្រើឲ្យផលប្រយោជន៍សាធារណៈ និងសមាជិក។

**ប្រការ៧ : សញ្ញាសម្គាល់ និងត្រា**

សញ្ញាសម្គាល់ និងត្រាអង្គការមានភ្ជាប់ឧបសម្ព័ន្ធមួយដោយឡែក ។ ត្រាអង្គការមានទំហំ៣៤ម.ម និងប្រើទឹកលក្តពណ៌ខៀវ ។

## ជំពូកទី ៣

## អំពីសមាជិក បុគ្គលិក និងការបាត់បង់សមាជិក បុគ្គលិកភាព

**ប្រការ៨ :** ប្រជាពលរដ្ឋទាំងពីរភេទដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅមានសិទ្ធិសុំចូលជាសមាជិកអង្គការបាន ។ សមាជិក និងបុគ្គលិកអង្គការទាំងអស់ត្រូវគោរពប្រតិបត្តិតាមច្បាប់នានាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងគោរពប្រតិបត្តិតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចផ្សេងៗរបស់អង្គការ ។

**សមាជិករបស់អង្គការមាន :**

-សមាជិកកិត្តិយស

-សមាជិកស្ថាបនិក

-សមាជិកសកម្ម ។

**ប្រការ៩ :** <u>សមាជិកកិត្តិយស</u> : គឺជាសមាជិកដែលបានជួយផ្តល់មូលនិធិ សម្ភារ បទពិសោធន៍ ឬមានស្នាដៃល្អជួយឲ្យអង្គការមានភាពរីកចម្រើន ។

**ប្រការ១០ :** <u>សមាជិកស្ថាបនិក</u> : គឺជាសមាជិកដែលបានផ្តួចផ្តើមគំនិតបង្កើតអង្គការនេះឡើង ។

**ប្រការ១១ :** <u>សមាជិកសកម្ម</u> : គឺជាសមាជិកដែលបានចូលរួមបម្រើសកម្មភាពការងារយ៉ាងសកម្មឲ្យអង្គការ ។

**ប្រការ១២ : អំពីការជ្រើសរើសបុគ្គលិក**

ការជ្រើសរើសបុគ្គលិកត្រូវអនុវត្តតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ច្បាប់ការងារ និងលិខិតបទដ្ឋានគតិយុត្តនានានៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ១៣ : អំពីការបាត់បង់សមាជិកភាព និងបុគ្គលិកភាព**

**លក្ខខណ្ឌនៃការបាត់បង់សមាជិកភាព និងបុគ្គលិកភាព :**

-ទទួលមរណភាព

-ចប់កិច្ចសន្យាការងារ

-បានដាក់ពាក្យសុំលាឈប់ដោយផ្ទាល់ខ្លួនជាលាយលក្ខណ៍អក្សរជូនគណៈកម្មការប្រតិបត្តិឲ្យបាន១៥ថ្ងៃមុនថ្ងៃឈប់ពីការងារ

-មិនគោរពតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចផ្សេងៗរបស់អង្គការ ហើយត្រូវបានបណ្តេញចេញដោយសេចក្តីសម្រេចចិត្តរបស់គណៈកម្មការប្រតិបត្តិតាមសំឡេងគាំទ្រ២/៣នៃសមាជិកគណៈកម្មការប្រតិបត្តិបន្ទាប់ពីបានទទួលការណែនាំពីគណៈកម្មការប្រតិបត្តិចំនួនពីរដងរួចហើយសាមីខ្លួននៅតែពុំព្រមកែប្រែខ្លួន

-មានជាប់ពិរុទ្ធពីបទល្មើសមជ្ឈិម ឬបទល្មើសព្រហ្មទណ្ឌណាមួយ ដែលចេញសាលក្រម ឬសាលដីកា

ស្ថាពរ ដោយតុលាការក្នុងព្រះរាជាណាចក្រកម្ពុជា

-មានជំងឺវិកលចរិត ដែលមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យស្របច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៤ :** ក្នុងករណីមានការបញ្ឈប់សមាជិក ឬ បុគ្គលិកណាមួយ គណៈកម្មការប្រតិបត្តិត្រូវជួបប្រជុំគ្នាដើម្បីជ្រើសរើសអ្នកមកជំនួសថ្មី ។

# ជំពូកទី ៤

## អំពីមេធាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច

**ប្រការ១៥ : សមាគមមានមេធាសម្ព័ន្ធគ្រប់គ្រងដូចខាងក្រោម :**

- សន្និបាត
- គណៈកម្មការប្រតិបត្តិ ។

**ប្រការ១៦ : សន្និបាតសាមញ្ញ** គឺប្រារព្ធធ្វើឡើងរៀងរាល់ ០១ឆ្នាំម្តងនៅក្នុងខែធ្នូ ដោយមានការចូលរួមពីគ្រប់សមាជិកទាំងអស់របស់អង្គការ ។សមាជិកកិត្តិយស មានសិទ្ធិចូលរួមក្នុងអង្គសន្និបាតបាន ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោត ឬ ឈរឈ្មោះឲ្យគេបោះឆ្នោតធ្វើជាប្រធានអង្គការបាននោះទេ ។

**<u>សន្និបាតសាមញ្ញមានភារកិច្ច</u>**

-បោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការប្រតិបត្តិនៅពេលចប់អាណត្តិ

-ពិនិត្យ វាយតម្លៃលើរបាយការណ៍ស្តីពីសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុ-ថវិកាដែលបានអនុវត្តកន្លងមក

-ពិនិត្យ និងអនុម័តលើទិសដៅ គោលបំណង និងថវិកាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់

-ពិនិត្យ និងអនុម័តលើការធ្វើវិសោធនកម្មលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង

-ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀតដែលស្នើឡើងដោយគណៈកម្មការប្រតិបត្តិ ។

**ប្រការ១៧ : សន្និបាតវិសាមញ្ញ**

ក្នុងករណីចាំបាច់ ឬ ពិសេសអង្គការអាចរៀបចំសន្និបាតវិសាមញ្ញបាន ដោយមិនកំណត់ពេលវេលា តាមការអញ្ជើញរបស់ប្រធានអង្គការ ឬ តាមសំណើសុំ ២/៣ នៃសមាជិកគណៈកម្មការប្រតិបត្តិរបស់អង្គការ ។

**<u>សន្និបាតវិសាមញ្ញមានភារកិច្ច</u>**

-ពិនិត្យ ពិភាក្សាកែប្រែ និងអនុម័តលក្ខន្តិកៈក្នុងករណីចាំបាច់

-ពិនិត្យ សម្រេចលើការផ្លាស់ប្តូរប្រធានអង្គការ

-ពិនិត្យ និងអនុម័តលើការផ្អាកសកម្មភាព រំលាយអង្គការ និងការចាត់ចែងទ្រព្យសម្បត្តិរបស់អង្គការ

-ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀតដែលចាំបាច់នៅក្នុងអង្គការ ។

**ប្រការ១៨ : លក្ខណៈគតិយុត្ត**

រាល់សេចក្តីសម្រេចរបស់សន្និបាតទាំងពីរប្រភេទមានតម្លៃគតិយុត្តបានលុះត្រាតែមានការអនុម័តដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត ៥០%+១ លើកូរ៉ុមចូលរួមក្នុងសន្និបាតយ៉ាងហោចណាស់ ២/៣ នៃសមាជិកគណៈកម្មការប្រតិបត្តិ ។ ក្នុងករណីមានសំឡេងស្មើគ្នាសំឡេងរបស់ប្រធានសន្និបាតមានឧត្តមនុភាព ។ ប្រធានសន្និបាតអាចជាប្រធានអង្គការ ឬ បុគ្គលដែលមានឯករាជ្យភាព តាមការជ្រើសរើសរបស់អង្គសន្និបាត ។

**ប្រការ១៩ : គណៈកម្មការប្រតិបត្តិ**

គណៈកម្មការប្រតិបត្តិមានសមាជិកយ៉ាងតិច០៣រូប និងមានអាណត្តិ០៥ឆ្នាំ ។ នៅពេលបញ្ចប់អាណត្តិនីមួយៗ សមាជិកគណៈកម្មការប្រតិបត្តិចាស់មានសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតជាថ្មីទៀតបាន ។

**ប្រការ២០ :** សមាជិកគណៈកម្មការប្រតិបត្តិជ្រើសតាំងឡើងតាមការបោះឆ្នោតដោយសំឡេងគាំទ្រ២/៣នៃសមាជិកគណៈកម្មការប្រតិបត្តិ និងមានសមាជិកដូចខាងក្រោម :

- ប្រធាន ០១ រូប
- អនុប្រធាន ០១ រូប
- រដ្ឋបាល/ហេរញ្ញិក ០១ រូប
- សមាជិក ។

**ប្រការ២១ : ប្រធានគណៈកម្មការប្រតិបត្តិ**

ប្រធានគណៈកម្មការប្រតិបត្តិគឺជាប្រធានអង្គការ និងជាតំណាងស្របច្បាប់របស់អង្គការ និងមានតួនាទីជាអ្នកទទួលបន្ទុកការងាររួម និងទទួលខុសត្រូវនូវគ្រប់សកម្មភាពរបស់អង្គការ ។

**ប្រការ២២ : អនុប្រធាន**

**មានតួនាទី និងភារកិច្ច :**

-មានតួនាទីជំនួសប្រធាននៅពេលប្រធានអវត្តមានក្នុងឋានៈជាប្រធានស្តីទីដោយមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធាន និងតាមការប្រគល់សិទ្ធិតាមការចាំបាច់របស់ប្រធាន ។

**ប្រការ២៣ : រដ្ឋបាល/ហេរញ្ញិក**

**មានតួនាទី និងភារកិច្ច :**

-គ្រប់គ្រងការងាររដ្ឋបាល ទ្រព្យសម្បត្តិសារពើភណ្ឌ

-រៀបចំលិខិតបទដ្ឋាន និងរក្សាតម្កល់ទុកឯកសារ

-គ្រប់គ្រងការងារបុគ្គលិក

-ធ្វើកំណត់ហេតុក្នុងអង្គប្រជុំ និងអង្គសន្និបាត

-គ្រប់គ្រង និងត្រួតពិនិត្យរាល់ចំណូល-ចំណាយរបស់អង្គការ

-ធ្វើគម្រោងថវិកាប្រចាំឆ្នាំ និងធ្វើរបាយការហិរញ្ញវត្ថុជូនប្រធានអង្គការ និងដាក់ជូនគណៈកម្មការប្រតិបត្តិ និងសន្និបាតពិនិត្យ សម្រេច

-គ្រប់គ្រង រៀបចំ និងត្រួតពិនិត្យរាល់គម្រោងរបស់អង្គការ ។

**ប្រការ២៤ : កិច្ចប្រជុំរបស់គណៈកម្មការប្រតិបត្តិ**

គណៈកម្មការប្រតិបត្តិត្រូវជួបប្រជុំគ្នា ០១ដងក្នុងមួយខែ តាមការអញ្ជើញរបស់ប្រធានអង្គការ និងអាចប្រជុំជាវិសាមញ្ញបានតាមការស្នើសុំរបស់ប្រធានអង្គការ ឬ២/៣ ប្រជុំជាវិសាមញ្ញបានតាមការស្នើសុំរបស់ប្រធានប្រជុំជាវិសាមញ្ញបានតាមការស្នើសុំរបស់ប្រធានអង្គការ ឬ២/៣ នៃសមាជិកគណៈកម្មការប្រតិបត្តិដើម្បីពិនិត្យ ពិភាក្សា អនុម័តលើរបៀបវារៈដែលបានដាក់ជូនដោយប្រធានអង្គការ ក្នុងគោលបំណងដើម្បីរិះរកយុទ្ធវិធីអនុវត្តសកម្មភាពការងារអង្គការឲ្យមានភាពរីកចម្រើន ។

**ប្រការ២៥ :** សេចក្តីសម្រេចរបស់អង្គប្រជុំ គណៈកម្មការប្រតិបត្តិទាំងពីរប្រភេទ មានលក្ខណៈគតិយុត្តបានតាមការអនុម័តដោយសំឡេងគាំទ្រ ៥០%+១លើកូរ៉ុមចូលរួម ២/៣ នៃសមាជិកគណៈកម្មការប្រតិបត្តិ ។

## ជំពូកទី ៥

### ចំណាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ

**ប្រការ២៦ :** លក្ខន្តិកៈរបស់អង្គការអាចប្តូរឈ្មោះ ប្តូររូបសញ្ញាសម្គាល់ និងធ្វើវិសោធនកម្មបានតាមសំណើសុំរបស់ប្រធានអង្គការ ឬតាមសំណូមពរ ២/៣ នៃសមាជិកគណៈកម្មការប្រតិបត្តិរបស់សមាគមការអនុម័តលើប្តូរឈ្មោះ ប្តូររូបសញ្ញាសម្គាល់ និងវិសោធនកម្មលក្ខន្តិកៈអង្គការជាសមត្ថកិច្ចរបស់សន្និបាត ។ មានតែសន្និបាតតែមួយគត់ដែលអាចសម្រេចប្តូរឈ្មោះ ប្តូររូបសញ្ញាសម្គាល់ និងធ្វើវិសោធនកម្មលក្ខន្តិកៈអង្គការបាន។

## ជំពូកទី ៦

### អំពីប្រភពមូលនិធិ និងការគ្រប់គ្រង

**ប្រការ២៧ : អង្គការមានប្រភពមូលនិធិមកពី :**

- ភាគទាន វិភាគទាន បរិនិសទានរបស់សមាជិក និងបុគ្គលិកអង្គការ
- អំណោយជាសម្ភារ ឬថវិកាពីបណ្តាសប្បុរសជននានា
- អំណោយពីអង្គការ-សមាគមជាតិ/អន្តជាតិនានា
- អំណោយពីរាជរដ្ឋាភិបាលកម្ពុជា
- អំណោយពីបណ្តាស្ថានទូត ឬ ភ្នាក់ងារផ្តល់ជំនួយនានា
- ចំណូលបានមកពីសកម្មភាពស្របច្បាប់របស់អង្គការ ។

## ជំពូកទី ៧

### ចំណាននៃការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ

**ប្រការ២៨ :** រាល់ចំណូលទាំងអស់របស់អង្គការត្រូវគ្រប់គ្រងដោយហេរញ្ញិករបស់អង្គការដោយមានការចុះហត្ថលេខាយល់ព្រមពីប្រធានអង្គការ ។ ចំណូលជាសាច់ប្រាក់ ឬ មូលប្បទានប័ត្រទាំងអស់ត្រូវបញ្ជូនទៅក្នុងគណនីធនាគាស្របច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងនាមអង្គការតាមការសម្រេចរបស់គណៈកម្មការប្រតិបត្តិ ។ ថវិកាអាចរក្សាទុកមួយចំនួននៅក្នុងបេឡារបស់អង្គការសម្រាប់ការប្រើប្រាស់ចាំបាច់ក្នុងអង្គការ តាមការកំណត់របស់គណៈកម្មការប្រតិបត្តិ រាល់ការដកសាច់ប្រាក់ ឬ មូលប្បទានប័ត្រពីធនាគារត្រូវមានចុះហត្ថលេខាដោយហេរញ្ញិក និងប្រធានអង្គការ ឬ អាចផ្ទេរសិទ្ធិទៅឲ្យរូបវន្តបុគ្គលដែលជាសមាជិកគណៈកម្មការប្រតិបត្តិតាមការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីសាមីខ្លួនដែលមានសិទ្ធិ ។

## ជំពូកទី ៨

### ការផ្អាកសកម្មភាព ការរំលាយ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ

**ប្រការ២៩ : ការផ្អាកសកម្មភាព**

មុនពេលអង្គការត្រូវបានផ្អាកសកម្មភាព សន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយដើម្បីជម្រះបញ្ជី

របស់អង្គការរាល់ទ្រព្យសម្បត្តិរបស់អង្គការដែលនៅសល់ក្រោយពីជម្រះបំណុលស្របច្បាប់របស់អង្គការរួចត្រូវផ្ទេរប្រគល់ជូនទៅអង្គការ ឬសមាគមស្របច្បាប់ណាមួយដែលមានគោលបំណងដូចអង្គការនេះឬប្រគល់ជូនសមាគមជាតិកាកបាទក្រហមកម្ពុជា ។ នៅពេលអង្គការផ្អាកសកម្មភាពសមាជិកអង្គការកុមារឃ្លាំងលើក៏ត្រូវផ្អាកសកម្មភាពផងដែរ ។ អង្គការអាចផ្អាកសកម្មភាពបានតាមសំណើសុំរបស់ប្រធានអង្គការឬ តាមសំណូមពរ២/៣នៃសមាជិកគណៈកម្មការប្រតិបត្តិរបស់អង្គការការអនុម័តលើផ្អាកសកម្មភាពអង្គការជាសមត្ថកិច្ចរបស់សន្និបាត ។

**ប្រការ៣០ :   ការរំលាយ**

មុនពេលអង្គការត្រូវបានរំលាយ សន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយដើម្បីជម្រះបញ្ជីរបស់អង្គការរាល់ទ្រព្យសម្បត្តិរបស់អង្គការដែលនៅសល់ក្រោយពីជម្រះបំណុលស្របច្បាប់របស់អង្គការ រួចត្រូវផ្ទេរប្រគល់ជូនទៅអង្គការ ឬ សមាគមស្របច្បាប់ណាមួយដែលមានគោលបំណងដូចអង្គការនេះឬប្រគល់ជូនសមាគមជាតិកាកបាទក្រហមកម្ពុជា។ នៅពេលអង្គការរំលាយសមាជិកអង្គការកុមារឃ្លាំងលើក៏ត្រូវរំលាយផងដែរ  អង្គការអាចរំលាយបានតាមសំណើសុំរបស់ប្រធានអង្គការ ឬ តាមសំណូមពរ  ២/៣  នៃសមាជិកគណៈកម្មការប្រតិបត្តិរបស់អង្គការការអនុម័តលើរំលាយអង្គការជាសមត្ថកិច្ចរបស់សន្និបាត  ។  សមាជិក  និងបុគ្គលិកទាំងអស់ក៏ត្រូវរំសាយដែរនៅពេលអង្គការរំលាយ ។

## ជំពូកទី ៩

## អវសានប្បញ្ញត្ត

**ប្រការ៣១ :**   រាល់បទប្បញ្ញត្តិទាំងឡាយណារបស់អង្គការកុមារឃ្លាំងលើ ដែលមានខ្លឹមសារផ្ទុយនឹងលក្ខន្តិកៈនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៣២ :**  អង្គការកុមារឃ្លាំងលើត្រូវធ្វើសកម្មភាពដោយអនុវត្តឲ្យស្របតាមលក្ខន្តិកៈរបស់ខ្លួនដូចដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ។

**ប្រការ៣៣ :**  លក្ខន្តិកៈរបស់អង្គការកុមារឃ្លាំងលើមានសុពលភាពគតិយុត្តពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី២២ ខែ វិច្ឆិកា  ឆ្នាំ២០១៦

**ជ.គណៈកម្មការប្រតិបត្តិ**

**ប្រធាន**

**កែវ  សំរិត**

បានតម្កល់ទុកលក្ខន្តិកៈ

របស់

.........អង្គការ កុមារឃ្លាំងលើ.........

ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ តាមប្រកាស

លេខៈ០២០........ប្រ.ក ចុះថ្ងៃទី០៣ខែ.មករា.ឆ្នាំ ២០១៧.។

រាជធានីភ្នំពេញ. ថ្ងៃទី.០៣..ខែ.មករា..ឆ្នាំ ២០១៧.

នាយកដ្ឋានកិច្ចការសមាគម  និងគណបក្សនយោបាយ

ប្រធាន

លក្ខន្តិកៈ

ស.អ

ឈឹម  ភាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# រចនាសម្ព័ន្ធអង្គការកុមារឃ្លាំងលើ

**សន្និបាត**

↓

**គណៈកម្មការប្រតិបត្តិ**

↓

**ប្រធាន**
កញ្ញា **កែវ សំរិត**

↓

**អនុប្រធាន**
លោកស្រី HANKARD FABIENNE ROLANDE ADRIENNE

↓

**រដ្ឋបាល/ហេរញ្ញិក**
លោក **នូ នាង**

↓

**សមាជិក**
លោកស្រី **ឈឹម ទេវី**

ថ្ងៃសៅរ៍ ១២កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ព្រះសីហនុ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២

**បានទទួលស្គាល់**
តាមលិខិតលេខ:៣៣៦៤សជណ ចុះថ្ងៃទី២១ ... ២៤
របស់ក្រសួងបហា...

**ជ.គណៈកម្មការប្រតិបត្តិ**
**ប្រធាន**

**កែវ សំរិត**

# សញ្ញាសម្គាល់ និងត្រាអង្គការកុមារឃ្លាំងលើ

១- សញ្ញាសម្គាល់

អង្គការកុមារឃ្លាំងលើ

Les Enfants De Klang Leu

២- ត្រា

ធ្វើនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦

**ប្រធាន**

**កែវ សំរិត**